**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ០៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា១:** ត្រូវបានបង្កើត នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២:** នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៣:** នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន មានភារៈកិច្ចធ្វើជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារអនុវត្តគោលនយោបាយហិរញ្ញវត្ថុវិមជ្ឈការ និងវិសហមជ្ឈការ និងមានតួនាទីភារៈកិច្ចសំខាន់ៗដូចខាងក្រោម :

**ក. ចំពោះ ហិរញ្ញវត្ថុ ឃុំ សង្កាត់**

- ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ របស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិ ឃុំ សង្កាត់
- ផ្តល់អនុសាសន៍ ស្តីពីគោលនយោបាយហិរញ្ញវត្ថុវិមជ្ឈការ និងកសាងលិខិតបទដ្ឋានក្របខ័ណ្ឌ គតិយុត្តិ នីតិវិធីសំរាប់បំពីអោយការអនុវត្តន៍ហិរញ្ញវត្ថុ ឃុំ សង្កាត់
- ចូលរួមរៀបចំ គំរោងថវិការដ្ឋប្រចាំឆ្នាំ ដើម្បីពិភាក្សានិងកំណត់ចំនួនផ្ទេរថវិកា សំរាប់មូលនិធិឃុំ សង្កាត់
- គ្រប់គ្រង និង តាមដានការផ្ទេរមូលនិធិឃុំ សង្កាត់ អោយបានទាន់ពេលវេលាតាមការកំណត់
- សហការ ជាមួយនាយកដ្ឋានជំនាញនៃក្រសួងមហាផ្ទៃ ស្ថាប័នដទៃទៀត ក្នុងការរៀបចំលិខិត បទដ្ឋាននានាសំរាប់បំពីដល់ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ជាសមភាគីការងារវិមជ្ឈការ ជាមួយស្ថាប័ន អង្គភាព ឬ ចូលរួមវេទិកានានា ស្តីពីកំណែទំរង់វិមជ្ឈការ ។

**ខ. ចំពោះ ហិរញ្ញវត្ថុ ខេត្ត ក្រុង**

- ផ្តល់អនុសាសន៍ ស្តីពីគោលនយោបាយហិរញ្ញវត្ថុវិសហមជ្ឈការនិងកសាងលិខិតបទដ្ឋានក្របខ័ណ្ឌគតិយុត្តិ នីតិវិធីសំរាប់បំពីអោយការអនុវត្តន៍ហិរញ្ញវត្ថុខេត្ត ក្រុង
- ពិគ្រោះយោបល់ជាមួយនាយកដ្ឋានជំនាញនៃក្រសួងមហាផ្ទៃ ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ វិធាននិងបទបញ្ញត្តិសំរាប់អនុវត្តថវិកាខេត្ត ក្រុង
- ទទួលខុសត្រូវក្នុងការរៀបចំគំរោងថវិកា និងការអនុវត្តន៍ថវិកាខេត្ត ក្រុង ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត ក្រុង
- រៀបចំធ្វើរបាយការណ៍អនុវត្តថវិកាខេត្ត ក្រុង
- ជាសមភាគីការងារវិសហមជ្ឈការ ជាមួយស្ថាប័នអង្គភាព ឬ ចូលរួមវេទិកានានា ស្តីពីកំណែទំរង់វិសហមជ្ឈការ ។

/ho

ឧបសម្ព័ន្ធអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ឆ្នាំ ២០០

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ



*មាត្រា៤:* ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីអង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសំរួលដូចឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងអនុក្រឹត្យនេះ ។

*មាត្រា៥:* ការបង្កើត ការរំសាយ និងការរៀបចំតួនាទី ភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

*មាត្រា៦:* បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

*មាត្រា៧:* រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>បានយកសេចក្តីជំរាបជូន:</u>
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចមាត្រា ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ